# ប្រកាសទទួលពាក្យស្នើសុំ

## ដាក់ពាក្យស្នើសុំជំនួយពី API សម្រាប់អង្គការសហគមន៍

វិទ្យាស្ថានតស៊ូមតិ និងគោលនយោបាយ (API) គឺជាអង្គការក្រៅរដ្ឋាភិបាលកម្ពុជាឈានមុខគេមួយ ដែលបម្រើដល់លទ្ធិប្រជាធិបតេយ្យរយៈពេលវែង និងការអភិវឌ្ឍសង្គមរបស់ប្រទេស ដោយការផ្តល់អំណាចដល់ពលរដ្ឋ។ ការផ្តោតមួយ ក្នុងចំណោមការយកចិត្តទុកដាក់ដទៃទៀត ដែលជាទម្លាប់មួយរបស់យើង គឺការតែងតែជួយធ្វើឲ្យអង្គការសហគមន៍ (CBOs) អាចតស៊ូមតិ សម្រាប់ការផ្លាស់ប្តូរគោលនយោបាយ នៅថ្នាក់មូលដ្ឋាន។ យោងតាមគោលដៅដែលបានកំណត់ នៅក្នុងផែនការយុទ្ធសាស្ត្រចុងក្រោយរបស់យើង (២០១៩-២០២៣) យើងមានចំណាប់អារម្មណ៍ជាពិសេស ក្នុងការឃើញស្ត្រី យុវជន និងក្រុមជួបការលំបាក ក្នុងការដើរតួនាទីឲ្យកាន់តែសកម្មថែមទៀត នៅក្នុងដំណើរការនៃការសម្រេចចិត្ត ក៏ដូចជានៅក្នុងជីវិតទូទៅសាធារណៈផងដែរ។

ដូច្នោះហើយ API បានសម្រេចចិត្ត ផ្តល់ជំនួយខ្នាតតូចដល់អង្គការសហគមន៍ ដែលតំណាងឲ្យក្រុមដែលបានលើកឡើងខាងលើ ដើម្បីលើកទឹកចិត្តពួកគេឲ្យចូលរួមបានកាន់តែច្រើន ជាមួយនឹងតំណាងរដ្ឋាភិបាលមូលដ្ឋាន ធ្វើឲ្យអាជ្ញាធរមានគណនេយ្យភាព និងស្នើសុំធ្វើឲ្យប្រសើរឡើងបន្ថែមនូវ សេវាកម្មសាធារណៈតាមការផ្តល់ជូន ក៏ដូចជាបរិយាកាសទូទៅ ដោយផ្អែកលើការឆ្លើយតប និងការរាប់បញ្ចូលយ៉ាងទូលំទូលាយ។ យ៉ាងហោចណាស់ ក៏មានជំនួយចំនួន ៨០ កញ្ចប់ដែរ ដែលនឹងត្រូវផ្តល់ជូន ជាមួយនឹងចំនួនទឹកប្រាក់ដែលមានទំហំចន្លោះពី ៥០០ ទៅ ៥០០០ ដុល្លារអាមេរិក ក្នុងមួយអង្គការ។

អង្គការសង្គមស៊ីវិល ដែលមានសិទ្ធិចូលរួម គួរតែមានយុវជន (ពលរដ្ឋមានអាយុចន្លោះពី ១៥ ទៅ ៣០ ឆ្នាំ) និង/ឬក៏ស្ត្រី ក្នុងតួនាទីជាអ្នកដឹកនាំ។ អង្គការគោលដៅរួមមាន ក្លឹបយុវជនក្នុងសហគមន៍ សាលារៀន ឬសាកលវិទ្យាល័យ ក្រុមជួយស្ត្រី ក្រុមជនពិការដែលជួយគ្នា សមាគមជនជាតិដើមភាគតិច អង្គការសហគមន៍ ដែលធ្វើការលើបញ្ហាទាក់ទងនឹងសហគមន៍ព្រៃឈើ ការនេសាទ ឬក្នុងវិស័យផ្សេងទៀត នៃការគ្រប់គ្រងធនធានធម្មជាតិ ជីវភាព និងការអភិវឌ្ឍក្នុងសហគមន៍ និងអង្គការដទៃទៀត ដែលមានមុខងារ ស្រដៀងគ្នា។ ជំនួយនេះ ត្រូវបានបង្កើតឡើងដើម្បីបង្កើតការសហការគ្នាជាមួយនឹងការគាំទ្រផ្នែកហិរញ្ញវត្ថុ របស់ដៃគូ ដែលមានស្រាប់ និងជាមួយការផ្តួចផ្តើមផ្សេងទៀត

វិទ្យាស្ថានតស៊ូមតិ និងគោលនយោបាយ
អគារ ភ្នំពេញវីឡា
ផ្ទះលេខ ១២៤ ផ្លូវ ៣៨៨ សង្កាត់ទួលស្វាយព្រៃទី១
ខណ្ឌចំការមន រាជធានីភ្នំពេញ
ព្រះរាជាណាចក្រកម្ពុជា
លេខទូរសព្ទ ០២៣ ២១៣ ៤៨៦
អ៊ីមែល apioffice@apiinstitute.org

## ប្រកាសទទួលពាក្យស្នើសុំ

ដែលមានគោលបំណងផ្តល់សិទ្ធិអំណាច ដល់បេក្ខភាពជាអង្គការសហគមន៍ ដើម្បីធ្វើការលើកកម្ពស់តម្លៃប្រជាធិបតេយ្យ អភិបាលកិច្ចល្អក្នុងមូលដ្ឋាន ការតស៊ូមតិ និងសិទ្ធិមនុស្ស។

អាទិភាព នឹងត្រូវបានផ្តល់ជូន ដល់ក្រុមយុវជន ឬក្រុមស្ត្រី ទាំងក្នុងផ្លូវការ និងក្រៅផ្លូវការ ក៏ដូចជាក្រុមសហគមន៍ផ្សេងទៀត ដែលមានថ្នាក់ដឹកនាំយ៉ាងរឹងមាំជាស្ត្រី និងយុវជន ដែលប្តេជ្ញាតស៊ូមតិ លើបញ្ហាសំខាន់មួយ ឬច្រើន ដូចដែលបានរៀបរាប់ខាងក្រោមនេះ៖

១. ការទទួលបាន/ការពង្រឹងសេវាសង្គមសាធារណៈ
២. ការធ្វើផែនការ និងថវិកា នៅថ្នាក់ក្រោមជាតិ
៣. ការគ្រប់គ្រងធនធានធម្មជាតិ (NRM) ការទទួលបានជាសាធារណៈ ឬសហគមន៍ និងសិទ្ធិអ្នកប្រើប្រាស់
៤. ការទទួលបាន/ការបង្ហាញ ព័ត៌មានសាធារណៈ ជាពិសេស ព័ត៌មានដែលទាក់ទងទៅនឹង ប្រាក់ចំណូលពីធនធានធម្មជាតិ ការវិនិយោគវិស័យឯកជន និងការបង្ហាញកិច្ចសន្យានៃវិស័យសាធារណៈ និងឯកជន

API ក៏នឹងកៀរគរមូលនិធិក្នុងមូលដ្ឋាន ដើម្បីគាំទ្រដល់ការផ្តួចផ្តើមខ្នាតតូចរបស់អង្គការសហគមន៍ ស្តីពីសកម្មភាពអប់រំ និងការអភិវឌ្ឍតាមសហគមន៍ ដោយរៀបចំការប្រជុំ រវាងអ្នកពាក់ព័ន្ធជាច្រើន ជាមួយក្រុមហ៊ុនឯកជនក្នុងស្រុក និងជាបុគ្គល។ ការផ្តួចផ្តើមតូចៗទាំងនេះ អាចត្រូវបានធ្វើផែនការ ដោយអង្គការសហគមន៍ ក្នុងកំឡុងពេលដែលពួកគេចូលរួមក្នុងការពិនិត្យឡើងវិញរួមគ្នាជាប្រព័ន្ធ នៃទិន្នន័យដែលមានលើបញ្ហាការអភិវឌ្ឍក្នុងមូលដ្ឋាន រួមនឹងអាទិភាព និងតម្រូវការរបស់ប្រជាពលរដ្ឋ។ ឧទាហរណ៍ នេះជាករណីប្រសិនបើ អង្គការសហគមន៍ចូលរួមយ៉ាងសកម្ម ក្នុងការអនុវត្តក្របខ័ណ្ឌគណនេយ្យភាពសង្គម (I-SAF) នៅក្នុងសហគមន៍របស់ពួកគេ ឬម្យ៉ាងទៀត បើពួកគេ ចូលរួមក្នុងការបង្ហាញផែនការអភិវឌ្ឍន៍ឃុំ ឬស្រុកនោះ។ បន្ទាប់មក ការផ្តួចផ្តើមខ្នាតតូច ក៏អាចត្រូវបានផ្តល់មូលនិធិពីក្នុងមូលដ្ឋានផងដែរ ដោយផ្អែកលើវេទិកានៃភាពជាដៃគូ ដែលរួមគ្នារវាងអង្គការសហគមន៍ វិស័យឯកជន និងតួអង្គរដ្ឋាភិបាលមូលដ្ឋាន។

លើសពីនេះទៅទៀត API ក៏ផ្តល់អំណាចដល់អង្គការសហគមន៍ ដោយការពង្រឹងជំនាញតស៊ូមតិ និងជួយក្នុងការបង្កើនសមត្ថភាពរបស់ពួកគេ ក្នុងការចូលរួមក្នុងកិច្ចសន្ទនា លើបញ្ហាសហគមន៍។

វិទ្យាស្ថានតស៊ូមតិ និងគោលនយោបាយ
អគារ ភ្នំពេញវីឡា
ផ្ទះលេខ ១២៤ ផ្លូវ ៣៨៨ សង្កាត់ទួលស្វាយព្រៃទី១
ខណ្ឌចំការមន រាជធានីភ្នំពេញ
ព្រះរាជាណាចក្រកម្ពុជា

លេខទូរសព្ទ ០២៣ ២១៣ ៤៨៦
អ៊ីមែល apioffice@apiinstitute.org

# ប្រកាសទទួលពាក្យស្នើសុំ

នៅក្នុងការជួបមុខគ្នាផ្ទាល់ ក្នុងកិច្ចប្រជុំ និងលើវេទិកាសាធារណៈ ឬដោយប្រើវេទិកាឌីជីថលសម្រាប់យុវជន ស្ត្រី និងក្រុមជួបការលំបាក អង្គការសហគមន៍ ដែលតំណាងឲ្យក្រុមជនទាំងនេះ មានឱកាសក្នុងការចែករំលែកទស្សនៈ និងយោបល់ពួកគេ លើបញ្ហា និងគោលនយោបាយ ដែលជះឥទ្ធិពលដល់ជីវិតរបស់ពួកគេ និងលើកកម្ពស់គណនេយ្យភាព និង តម្លាភាព នៃស្ថាប័នសាធារណៈ ដែលមានដូចជា សាលាបឋមសិក្សា មណ្ឌលសុខភាព រួមមានទាំងរដ្ឋបាល ឃុំ សង្កាត់ ស្រុក ខណ្ឌ និងក្រុងផងដែរ។ API យកចិត្តទុកដាក់ជាពិសេស ដល់ក្រុមជនងាយរងគ្រោះ ដោយទទូចថា ឲ្យពួកគេត្រូវបានទទួលសិទ្ធិ ក្នុងការទទួលបានការអប់រំ និងសុខភាព ប្រកបដោយការយល់ដឹង ការរាប់បញ្ចូល ភាពស្មើគ្នា និងប្រកបដោយគុណភាព ព្រមទាំងសេវាកម្មក្នុងមូលដ្ឋានដទៃទៀត ដែលផ្តល់ដោយរដ្ឋបាលទាំងនោះ រួមទាំងសេវាកម្មសង្គមផងដែរ។

សូមដាក់ស្នើនូវទម្រង់ពាក្យស្នើសុំជំនួយរបស់អ្នក ដោយប្រើទម្រង់ ដែលបានភ្ជាប់មកជាមួយនោះ។

វិទ្យាស្ថានតស៊ូមតិ និងគោលនយោបាយ
អគារ ភ្នំពេញវិទ្យា
ផ្ទះលេខ ១២៤ ផ្លូវ ៣៨៨ សង្កាត់ទួលស្វាយព្រៃទី១
ខណ្ឌចំការមន រាជធានីភ្នំពេញ
ព្រះរាជាណាចក្រកម្ពុជា

លេខទូរសព្ទ ០២៣ ២១៣ ៤៨៦
អ៊ីមែល apioffice@apiinstitute.org